**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ : ០១៧ សជណ ....... សក.អល

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ...... ខែ មិថុនា ... ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ ការទិញរថយន្តសម្រាប់ជួសជុលរថយន្តចំនួន ២០គ្រឿង ឆ្នាំ ២០១៦

ក្រសួងសាធារណការ និងដឹកជញ្ជូន សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក(គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកជួសជុលរថយន្តចំនួន ២០គ្រឿង ឆ្នាំ ២០១៦ ។

ក្រសួងសាធារណការ និងដឹកជញ្ជូន បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានអាសយដ្ឋានអគារមហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី ១៧ ...... ខែ មិថុនា .... ឆ្នាំ ២០១៦ តទៅរៀងរាល់ម៉ោងធ្វើការ (លេខទូរស័ព្ទទំនាក់ទំនង ០១១ ៨៣៥ ៨៥៧) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូន អង្គភាពលទ្ធកម្ម នៃក្រសួងសាធារណការ និងដឹកជញ្ជូន យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៨ ...... ខែ កក្កដា ... ឆ្នាំ ២០១៦ វេលាម៉ោង ០៩ : ៣០ព្រឹក ....... ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅ អង្គភាពលទ្ធកម្ម នៃក្រសួងសាធារណការ និងដឹកជញ្ជូន តាមអាសយដ្ឋានខាងលើ វេលាម៉ោង ០៩:៣០ព្រឹក ថ្ងៃទី ១៨ ...... ខែ កក្កដា ........ ឆ្នាំ ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយ អង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

ស៊ុន ចាន់ថុល

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ



មហាវិថី ព្រះនរោត្តម, ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥) ២៣ ៤២៦ ៦៤០, (៨៥៥) ២៣ ៤២៧ ៨៦២